ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ៧២១២ មស.៩៨៧

# សេចក្ដីជូនដំណឹង
## ស្ដីពី
## ការប្រឡងប្រជែងជ្រើសរើសបេក្ខជន សិស្ស និស្សិត ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងមុខងារសាធារណៈ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច ក្រសួងទេសចរណ៍ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងធម្មការនិងសាសនា និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

**យោង ៖**
- លិខិតលេខ៩៥៣ មស.ក្រខ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៥ របស់ក្រសួងមុខងារសាធារណៈ
- យោងលិខិតលេខ៤៨០/១៥ ទរពអ.រប ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៥ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច
- លិខិតលេខ៥៣៤ លស.អរហ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥ របស់ក្រសួងទេសចរណ៍
- លិខិតលេខ៦៤៦ បទ.បប ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៥ របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- លិខិតលេខ៧៨៩ ធទឧ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៥ របស់ក្រសួងធនធានទឹក និងឧតុនិយម
- លិខិតលេខ២៨០/១៥ ក.ធ.ស ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៥ របស់ក្រសួងធម្មការ និងសាសនា
- លិខិតលេខ០៦៧០ រលអស ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៥ របស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ប្រកាសលេខ២០៧៦ មស.ប្រក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៥ របស់ក្រសួងមុខងារសាធារណៈ ស្ដីពីការបង្កើតគណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសបេក្ខជន សិស្ស និស្សិត ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងមុខងារសាធារណៈ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច ក្រសួងទេសចរណ៍ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងធម្មការនិងសាសនា និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- លិខិតលេខ២១៦៨ មស.ក្រខ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៥ របស់ក្រសួងមុខងារសាធារណៈ
- យោងតាមការចាំបាច់ និងសំណូមពរការងារ។

ក្រសួងមុខងារសាធារណៈ សូមជូនដំណឹងដល់បេក្ខជន សិស្ស និស្សិត និងសាធារណជនទាំងអស់ឱ្យបានជ្រាបថា ក្រសួងបាននឹងកំពុងរៀបចំធ្វើការប្រឡងប្រជែងជ្រើសរើសបេក្ខជនមានសញ្ជាតិខ្មែរទាំងពីរភេទចំនួន ១១៨នាក់ ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួង-ស្ថាប័នចំនួនប្រាំពីរ សម្រាប់ក្របខណ្ឌឆ្នាំ២០១៥ ក្នុងនោះរួមមាន ៖

**១-ក្រសួងមុខងារសាធារណៈ ចំនួន ១២នាក់**

ក្របខណ្ឌប្រភេទ **ក** ចំនួន ១២នាក់ បេក្ខជនត្រូវមានសញ្ញាបត្រចាប់ពីថ្នាក់បរិញ្ញាបត្រឡើងទៅផ្នែក ទេសចរណ៍ និងបដិសណ្ឋារកិច្ច ភាសាអង់គ្លេស ព័ត៌មានវិទ្យា ទំនាក់ទំនងអន្តរជាតិ រដ្ឋបាលសាធារណៈ វិភាគទិន្នន័យ គណិតវិទ្យា នីតិសាស្ត្រ គណនេយ្យ-ហិរញ្ញវត្ថុ សេដ្ឋកិច្ច ស្ថិតិ សវនកម្ម ឬសញ្ញាបត្រសមមូលដូចមានខាងក្រោម ៖

ផ្លូវវត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

| ល.រ | អង្គភាព | ចំនួនជ្រើសរើស | ប្រភេទក្រ.ខ |
|---|---|---|---|
| ១ | នាយកដ្ឋានរដ្ឋបាលនិងសរុប | ០១នាក់ | ក |
| ២ | នាយកដ្ឋានផែនការ ហិរញ្ញវត្ថុនិងផ្គត់ផ្គង់ | ០១នាក់ | ក |
| ៣ | ន. នីតិកម្ម និងវិវាទមុខងារសាធារណៈ | ០១នាក់ | ក |
| ៤ | ន.គ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា និងឯកសារមន្ត្រីរាជការស៊ីវិល | ០១នាក់ | ក |
| ៥ | មជ្ឈមណ្ឌលធនធានអាស៊ានកម្ពុជា និងកិច្ចសហប្រតិបត្តិការអន្តរជាតិ | ០១នាក់ | ក |
| ៦ | ន. សេវាសាធារណៈ | ០១នាក់ | ក |
| ៧ | ន. អភិវឌ្ឍន៍ធនធានមនុស្ស និងស្ថាប័ន | ០១នាក់ | ក |
| ៨ | ន.គោលនយោបាយលាភការនិងសមិទ្ធកម្ម | ០១នាក់ | ក |
| ៩ | ន.សម្របសម្រួលការកែទម្រង់អន្តរវិស័យ | ០១នាក់ | ក |
| ១០ | ន.ត្រួតពិនិត្យ និងវាយតម្លៃ | ០១នាក់ | ក |
| ១១ | ន. សវនកម្មផ្ទៃក្នុង | ០១នាក់ | ក |
| ១២ | អគ្គាធិការដ្ឋាន | ០១នាក់ | ក |
| សរុប | | ១២នាក់ | |

**២-ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច ចំនួន ០៦នាក់**

ក្របខណ្ឌប្រភេទ ក ចំនួន ០៦នាក់ បេក្ខជនត្រូវមានសញ្ញាបត្រចាប់ពីថ្នាក់បរិញ្ញាបត្រឡើងទៅ ឬសញ្ញាបត្រសមមូល ។

**៣-ក្រសួងទេសចរណ៍ ចំនួន ១២នាក់**

ក្របខណ្ឌប្រភេទ ក ចំនួន ១២នាក់ បេក្ខជនត្រូវមានសញ្ញាបត្រចាប់ពីថ្នាក់បរិញ្ញាបត្រឡើងទៅ ឬសញ្ញាបត្រសមមូល ជំនាញទេសចរណ៍ ភាសាអង់គ្លេស ព័ត៌មានវិទ្យា នីតិសាស្ត្រ និងមុខជំនាញប្រហាក់ប្រហែលផ្សេងទៀតដែលមានឧបនិស្ស័យទេសចរណ៍ ក្នុងនោះរួមមាន៖

១-មន្ទីរទេសចរណ៍រាជធានីភ្នំពេញ ចំនួន ០២នាក់
២-មន្ទីរទេសចរណ៍ខេត្តកំពង់ឆ្នាំង ចំនួន ០២នាក់
៣-មន្ទីរទេសចរណ៍ខេត្តកំពង់ធំ ចំនួន ០១នាក់
៤-មន្ទីរទេសចរណ៍ខេត្តតាកែវ ចំនួន ០១នាក់
៥-មន្ទីរទេសចរណ៍ខេត្តកំពង់ចាម ចំនួន ០៣នាក់
៦-មន្ទីរទេសចរណ៍ខេត្តត្បូងឃ្មុំ ចំនួន ០៣នាក់

**៤-ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ចំនួន ៣១នាក់**

ក្របខណ្ឌប្រភេទ ក ចំនួន ៣១នាក់ បេក្ខជនត្រូវមានសញ្ញាបត្រចាប់ពីថ្នាក់បរិញ្ញាបត្រឡើងទៅ ឬសញ្ញាបត្រសមមូល ដូចខាងក្រោម ៖

I. ទីស្តីការក្រសួង ចំនួន ២៦នាក់

១. ជំនាញព័ត៌មានវិទ្យា ចំនួន ១២នាក់
២. ជំនាញគ្រប់គ្រង ចំនួន ០៣នាក់
៣. ជំនាញហិរញ្ញវត្ថុ ចំនួន ០៤នាក់
៤. ជំនាញនីតិសាស្ត្រ ចំនួន ០៣នាក់
៥. ជំនាញភាសាអង់គ្លេស ចំនួន ០២នាក់
៦. ជំនាញវិស្វកម្មអគ្គីសនី ចំនួន ០២នាក់

II. មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តត្បូងឃ្មុំ ចំនួន ០៥នាក់

១. ជំនាញព័ត៌មានវិទ្យា ចំនួន ០២នាក់
២. ជំនាញហិរញ្ញវត្ថុ ចំនួន ០២នាក់
៣. ជំនាញគ្រប់គ្រង ចំនួន ០១នាក់

**៥-ក្រសួងធនធានទឹកនិងឧតុនិយម ចំនួន ៤០នាក់**

ក្របខណ្ឌប្រភេទ **ក** ចំនួន ៤០នាក់ បេក្ខជនត្រូវមានសញ្ញាបត្រចាប់ពីថ្នាក់បរិញ្ញាបត្រឡើងទៅ ឬសញ្ញាបត្រសមមូលដូចខាងក្រោម ៖

១. ជំនាញទេពកោសល្យជនបទ ចំនួន ០៥នាក់
២. ជំនាញសំណង់ស៊ីវិល ចំនួន ០៥នាក់
៣. ជំនាញសំណង់ធារាសាស្ត្រ ចំនួន ០៥នាក់
៤. ជំនាញស្ថាបត្យកម្ម ចំនួន ០៤នាក់
៥. ជំនាញព័ត៌មានវិទ្យា ចំនួន ០៤នាក់
៦. ជំនាញឧតុនិយម ចំនួន ០២នាក់
៧. ជំនាញជលសាស្ត្រ ចំនួន ០២នាក់
៨. ជំនាញនីតិសាស្ត្រ ចំនួន ០២នាក់
៩. ជំនាញគ្រប់គ្រង ចំនួន ០២នាក់
១០. ជំនាញគណនេយ្យ-ហិរញ្ញវត្ថុ ចំនួន ០៤នាក់
១១. ជំនាញភាសាអង់គ្លេស ចំនួន ០៤នាក់
១២. ជំនាញភាសាបារាំង ចំនួន ០១នាក់

**៦-ក្រសួងធម្មការនិងសាសនា ចំនួន ០៦នាក់**

ក្របខណ្ឌប្រភេទ **ក** ចំនួន ០៦នាក់ បេក្ខជនត្រូវមានសញ្ញាបត្រចាប់ពីថ្នាក់បរិញ្ញាបត្រឡើងទៅ ឬសញ្ញាបត្រសមមូលដូចខាងក្រោម ៖

១. ជំនាញព័ត៌មានវិទ្យា ចំនួន ០១នាក់
២. ជំនាញអក្សរសាស្ត្រអង់គ្លេស ចំនួន ០២នាក់
៣. ជំនាញនីតិសាស្ត្រ ចំនួន ០១នាក់
៤. ជំនាញគណនេយ្យ-ហិរញ្ញវត្ថុ ចំនួន ០២នាក់

**៧-រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ចំនួន ១១នាក់**

**ក. រដ្ឋបាលថ្នាក់កណ្តាល**

១. ក្របខណ្ឌប្រភេទ **ក** ចំនួន ០៦នាក់ ក្នុងនោះស្រី ០១នាក់ បេក្ខជនត្រូវមាន សញ្ញាបត្រចាប់ពីថ្នាក់បរិញ្ញាបត្រឡើងទៅ ឬសញ្ញាបត្រសមមូល ផ្នែកភាសាអង់គ្លេស, អក្សរសាស្ត្រអង់គ្លេស, នីតិសាស្ត្រ, គណនេយ្យ-ហិរញ្ញវត្ថុ សិល្បសាស្ត្រ និងគ្រប់គ្រងពាណិជ្ជកម្ម ។

២. ក្របខណ្ឌប្រភេទ **ខ** ចំនួន ០១នាក់ ជាស្រី បេក្ខជនត្រូវមានសញ្ញាបត្រចាប់ពីថ្នាក់បរិញ្ញាបត្ររងឡើងទៅ ឬសញ្ញាបត្រសមមូលផ្នែកគ្រប់គ្រង ។

**ខ.ការិយាល័យផ្តល់សេវាកម្មឧតុនិយម ផ្នែកអង្កេតអាកាសធាតុ នៅអាកាសយានដ្ឋានអន្តរជាតិ ខេត្តព្រះសីហនុ**

ក្របខណ្ឌប្រភេទ **ក** ចំនួន ០៤នាក់ ក្នុងនោះស្រី ០៣នាក់ បេក្ខជនត្រូវមាន សញ្ញាបត្រចាប់ពីថ្នាក់បរិញ្ញាបត្រឡើងទៅ ឬសញ្ញាបត្រសមមូលផ្នែកសេដ្ឋកិច្ច, គណនេយ្យ ហិរញ្ញវត្ថុ, ហិរញ្ញវត្ថុ ធនាគារ និងគណនេយ្យ។

បញ្ជាក់៖ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល មិនធានាកន្លែងស្នាក់នៅសំរាប់បេក្ខជនដែលបម្រើការងារនៅអាកាសយានដ្ឋានអន្តរជាតិ ខេត្តព្រះសីហនុឡើយ។

**បញ្ជាក់៖** * វិញ្ញាសា និងរយៈពេលប្រឡងត្រូវបានកំណត់ដូចខាងក្រោម ៖

១.ក្រសួងមុខងារសាធារណៈ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងធម្មការនិងសាសនា និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

- ចំណេះដឹងទូទៅពាក់ព័ន្ធនឹងមុខងារសាធារណៈ រយៈពេល ០២ម៉ោង ទៅតាមប្រភេទក្របខណ្ឌ **ក** និង **ខ**
- មុខវិជ្ជាភាសាអង់គ្លេសនិងកុំព្យូទ័រ រយៈពេល ១ម៉ោង៣០នាទី ទៅតាមប្រភេទក្របខណ្ឌ **ក** និង **ខ** ។

២. ក្រសួងទេសចរណ៍

- ចំណេះដឹងទូទៅពាក់ព័ន្ធទៅនឹងវិស័យទេសចរណ៍ រយៈពេល ០២ម៉ោង ទៅតាមប្រភេទក្របខណ្ឌ **ក**
- មុខវិជ្ជាភាសាអង់គ្លេសនិងកុំព្យូទ័ររយៈពេល ១ម៉ោង៣០នាទី ទៅតាមប្រភេទក្របខណ្ឌ **ក** ។

* សញ្ញាបត្រ ឬលិខិតបញ្ជាក់ការសិក្សា គ្រប់កម្រិតជំនាញត្រូវបានដាក់វិធានការដូចខាងក្រោម ៖

ក្នុងករណីរកឃើញមានការក្លែងបន្លំសញ្ញាបត្រ ឬលិខិតស្នាមផ្សេងៗ បេក្ខជននឹងត្រូវលុបឈ្មោះចេញជាស្វ័យប្រវត្តិ ទោះបីជាបេក្ខជននោះប្រឡងជាប់ក្នុងក្របខណ្ឌក្រសួង-ស្ថាប័នណាមួយក៏ដោយ និងត្រូវផ្តន្ទាទោសពីបទក្លែងលិខិតរដ្ឋបាលសាធារណៈ ។

ចំពោះសញ្ញាបត្រដែលបានបញ្ចប់ការសិក្សាពីបរទេស ត្រូវយកទៅបញ្ជាក់ជាភាសាជាតិ ដោយមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។

ចំពោះកាលបរិច្ឆេទប្រឡង មណ្ឌលប្រឡង និងបញ្ជីរាយនាមរបស់បេក្ខជន គណៈកម្មការរៀបចំការប្រឡងនឹងបិទផ្សាយជាសាធារណៈ និងនៅក្រសួងមុខងារសាធារណៈ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច ក្រសួងទេសចរណ៍ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងធម្មការនិងសាសនា និងរដ្ឋលេខាធិការដ្ឋាន អាកាសចរស៊ីវិល។

បេក្ខជនដែលមានចំណាប់អារម្មណ៍ ត្រូវប្រញាប់មកទទួលពាក្យដើម្បីបំពេញសំណុំបែបបទប្រឡងប្រជែងជ្រើសរើសតាមក្រសួង-ស្ថាប័នណាមួយដែលខ្លួនមានបំណងចង់ចូលបម្រើការងារដូចបានរៀបរាប់ខាងលើនេះ នៅនាយកដ្ឋានគ្រប់គ្រងក្របខ័ណ្ឌ នៃក្រសួងមុខងារសាធារណៈ និងនៅនាយកដ្ឋានបុគ្គលិកក្រសួង ស្ថាប័នពាក់ព័ន្ធ រៀងរាល់ម៉ោង និងថ្ងៃធ្វើការ ។

១. កាលបរិច្ឆេទនៃការផ្តល់ពាក្យចាប់ពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៥

២. កាលបរិច្ឆេទនៃការឈប់ទទួលពាក្យថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥

*កំណត់សម្គាល់* ៖ ក្រសួងមុខងារសាធារណៈ រក្សាសិទ្ធិក្នុងការកែប្រែសេចក្តីជូនដំណឹងនេះ ក្នុងករណីចាំបាច់ ៕

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងតាមទូរស័ព្ទ ៖

- ០៨៧ ៥៣ ៥៣ ៨៨ / ០១២ ៣៥១ ១១៤ / ០៧៧ ៨២ ៨២ ៥៣ / ០១៧ ៦៥១ ៣២៣

រាជធានីភ្នំពេញ,ថ្ងៃទី២៤ខែ សីហា ឆ្នាំ២០១៥

**រដ្ឋលេខាធិការ និងជា**

**ប្រធានគណៈកម្មការរៀបចំការប្រឡង**

**យូ ស៊ុនឡុង**

**ចម្លងជូន៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
" ដើម្បីជូនជ្រាប "
-ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច
-ក្រសួងទេសចរណ៍
-ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
-ក្រសួងធនធានទឹកនិងឧតុនិយម
-ក្រសួងធម្មការនិងសាសនា
-រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
" ដើម្បីសហការផ្សព្វផ្សាយនិងអនុវត្ត "
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ២២០៩ មស.សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការកំណត់លក្ខណៈវិនិច្ឆ័យ
# នៃការប្រឡងប្រជែងជ្រើសរើសបេក្ខជន សិស្ស និស្សិត
# ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងមុខងារសាធារណៈ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច ក្រសួងទេសចរណ៍ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងធម្មការនិងសាសនា និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

## រដ្ឋមន្ត្រី ក្រសួងមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នសរកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- សារាចរលេខ០១ សរ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៥ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីវិធានការសម្រាប់ការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល យោធិន នគរបាលជាតិ មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែតក្នុងឆ្នាំ២០១៥
- លិខិតលេខ៩៥៣ មស.ក្រខ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៥ របស់ក្រសួងមុខងារសាធារណៈ
- ប្រកាសលេខ២០៧៦ មស.ប្រក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៥ របស់ក្រសួងមុខងារសាធារណៈ ស្តីពីការបង្កើតគណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសបេក្ខជន សិស្ស និស្សិត ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងមុខងារសាធារណៈ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច ក្រសួងទេសចរណ៍ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងធម្មការនិងសាសនា និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- លិខិតលេខ២១៦៨ មស.ក្រខ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៥ របស់ក្រសួងមុខងារសាធារណៈ
- យោងតាមការចាំបាច់ និងសំណូមពរការងារ ។



ផ្លូវវត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

## សម្រេច

**ប្រការ១៖** បើកឱ្យមានការប្រឡងប្រជែងជ្រើសរើសបេក្ខជន សិស្ស និស្សិត ទូទាំងព្រះរាជាណាចក្រកម្ពុជា ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួង-ស្ថាប័នទាំងប្រាំពីរ ដែលមានលក្ខណៈសម្បត្តិសមស្របតាមកម្រិតក្របខណ្ឌ **ក** និង **ខ** សម្រាប់ឆ្នាំ២០១៥ ដូចមានខាងក្រោម៖

| | |
|---|---|
| ១-ក្រសួងមុខងារសាធារណៈ | ចំនួន ១២នាក់ |
| ២-ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច | ចំនួន ០៦នាក់ |
| ៣-ក្រសួងទេសចរណ៍ | ចំនួន ១២នាក់ |
| ៤-ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ចំនួន ៣១នាក់ |
| ៥-ក្រសួងធនធានទឹកនិងឧតុនិយម | ចំនួន ៤០នាក់ |
| ៦-ក្រសួងធម្មការនិងសាសនា | ចំនួន ០៦នាក់ |
| ៧-រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | ចំនួន ១១នាក់ |

**ប្រការ២៖** ការប្រឡងប្រជែងជ្រើសរើសបេក្ខជន សិស្ស និស្សិត ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌ ក្រសួងមុខងារសាធារណៈ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច ក្រសួងទេសចរណ៍ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងធម្មការនិងសាសនា និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សម្រាប់ផែនការក្របខណ្ឌឆ្នាំ២០១៥ នេះ *ចាត់ទុកជាការប្រញាប់*។

**ប្រការ៣៖** បេក្ខជនទាំងពីរភេទ មានសិទ្ធិអាចសុំចុះឈ្មោះប្រឡងប្រជែងបាន ត្រូវមានលក្ខខណ្ឌដូចខាងក្រោម៖

I- លក្ខខណ្ឌនៃការជ្រើសរើស

១-មានសញ្ជាតិខ្មែរ

២-មានអាយុយ៉ាងតិច ១៨ឆ្នាំ ហើយមិនលើសពី ២៥ឆ្នាំ ប៉ុន្តែមានករណីលើកលែងខ្លះដូចមានចែងខាងក្រោម៖

ក-ចំពោះបេក្ខជនដែលមានសញ្ញាបត្រឧត្តមសិក្សា ការកម្រិតអាយុត្រូវបានរំកិលពី ២៥ឆ្នាំ ដល់៣០ឆ្នាំ យ៉ាងច្រើនបំផុត។

ខ-ចំពោះបេក្ខជនដែលបានរៀននៅគ្រឹះស្ថានឧត្តមសិក្សាមួយឆ្នាំឬច្រើនឆ្នាំហើយមិនមានសញ្ញាបត្រនោះ ការកម្រិតអាយុ២៥ឆ្នាំនឹងត្រូវរំកិលតាមចំនួនឆ្នាំដែលបានរៀនក្នុងគ្រឹះស្ថានឧត្តមសិក្សាទាំងនោះតែមិនឱ្យលើសពីអាយុ ៣០ឆ្នាំ។

៣-មិនប្រាសចាកសិទ្ធខាងផ្លូវរដ្ឋប្បវេណី សិទ្ធពលរដ្ឋ និងសិទ្ធខាងនយោបាយ។

៤-ចំពោះបេក្ខជនជាជនជាតិភាគតិច អ្នកនៅតំបន់ដាច់ស្រយាល នារីភេទ និងជនពិការ ត្រូវបានផ្តល់អាទិភាព និងលើកទឹកចិត្តសម្រាប់ការប្រឡងប្រជែងជ្រើសរើសនេះ។

បញ្ជាក់៖បេក្ខជនប្រឡងប្រជែងចូលក្របខណ្ឌទាំង០៧ (ប្រាំពីរ) ក្រសួង ស្ថាប័ន សម្រាប់ឆ្នាំ២០១៥ ខាងលើនេះ ត្រូវគិតលក្ខខណ្ឌអាយុដូចខាងក្រោម៖

-បេក្ខជនប្រឡងចូលក្របខណ្ឌ **ក** ត្រូវមានឆ្នាំកំណើតចាប់ពី ឆ្នាំ១៩៨៥ ឡើងទៅ

-បេក្ខជនប្រឡងចូលក្របខណ្ឌ **ខ** ត្រូវមានឆ្នាំកំណើតចាប់ពី ឆ្នាំ១៩៨៧ ឡើងទៅ

II-សំណុំលិខិតដែលត្រូវបំពេញមាន ៖

| | |
|---|---|
| ១-ពាក្យសុំចុះឈ្មោះប្រឡង.......................................................................... | ចំនួន ០១ច្បាប់ |
| ២-ជីវប្រវត្តិសង្ខេប................................................................................ | ចំនួន ០១ច្បាប់ |
| ៣-សលាកប័ត្រឯកត្តជន.............................................................................. | ចំនួន ០១ច្បាប់ |
| ៤-បង្កាន់ដៃទទួលពាក្យសុំសិទ្ធិប្រឡង | ចំនួន ០១ច្បាប់ |

៥-សេចក្តីចម្លងសញ្ញាបត្រដោយមានបញ្ជាក់ជាផ្លូវការពីអាជ្ញាធរមានសមត្ថកិច្ច ចំនួន ០១ច្បាប់

៦-លិខិតបញ្ជាក់សុខភាព ( មិនលើសពីរយៈពេលបីខែ គិតមកដល់ថ្ងៃប្រឡង )
ដែលចេញដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន ០១ច្បាប់

៧-សេចក្តីថតចម្លងសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ចំនួន ០១ច្បាប់

៨-លិខិតបញ្ជាក់កិរិយាមារយាទ (ចេញដោយអាជ្ញាធរមូលដ្ឋាន) ចំនួន ០១ច្បាប់

៩-លិខិតថ្កោលទោសផ្តល់ជូនក្រោយពេលប្រឡងជាប់រយៈពេល ៣ខែយ៉ាងយូរ ចំនួន ០១ច្បាប់

១០-រូបថត 4 x 6 ចំនួន ០២សន្លឹក

**ប្រការ៤៖** វិញ្ញាសានិងថេរវេលា នៃការប្រឡងប្រជែងរួមមាន ៖

១.ក្រសួងមុខងារសាធារណៈ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងធម្មការនិងសាសនា និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ៖

- ចំណេះដឹងទូទៅពាក់ព័ន្ធនឹងមុខងារសាធារណៈ រយៈពេល ០២ម៉ោង ទៅតាមប្រភេទក្របខណ្ឌ **ក** និង **ខ**
- មុខវិជ្ជាភាសាអង់គ្លេសនិងកុំព្យូទ័រ រយៈពេល ១ម៉ោង៣០នាទី ទៅតាមប្រភេទក្របខណ្ឌ **ក** និង **ខ** ។

២. ក្រសួងទេសចរណ៍

- ចំណេះដឹងទូទៅពាក់ព័ន្ធទៅនឹងវិស័យទេសចរណ៍ រយៈពេល ០២ម៉ោង ទៅតាមប្រភេទ ក្របខណ្ឌ **ក**
- មុខវិជ្ជាភាសាអង់គ្លេសនិងកុំព្យូទ័ររយៈពេល ១ម៉ោង៣០នាទី ទៅតាមប្រភេទក្របខណ្ឌ **ក** ។

**ប្រការ៥៖** លក្ខណៈវិនិច្ឆ័យនានាជាលម្អិត ពាក់ព័ន្ធទៅនឹងការប្រឡងប្រជែងខាងលើនេះ ត្រូវកំណត់ដោយគណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសបេក្ខជន ឱ្យចូលបម្រើការងារក្នុងក្រសួង-ស្ថាប័នទាំងប្រាំពីរ។

**ប្រការ៦៖** អគ្គនាយកនៃអគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានគ្រប់គ្រងក្របខ័ណ្ឌ ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវសហការនិងទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ,ថ្ងៃទី២៤ខែសីហាឆ្នាំ២០១៥

**រដ្ឋមន្ត្រី**

**ពេជ្រ ប៊ុនធិន**

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-ក្រសួងអប់រំ យុវជន និងកីឡា
" ដើម្បីជូនជ្រាប "
-ក្រសួង-ស្ថាប័នពាក់ព័ន្ធ " សហការផ្សព្វផ្សាយ "
-ដូចប្រការ៦ (ដើម្បីអនុវត្ត)
-ឯកសារ-កាលប្បវត្តិ